# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៣៥៩៥
ចុះថ្ងៃទី ១៦.១១.២០១២

សាលក្រម
លេខ ៨៧ "យ"
ចុះថ្ងៃទី ២២.១០.២០១៣

## គាំទនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២២ ខែតុលា ឆ្នាំ២០១៣ ដែលមានសមាសភាព ជំនុំជម្រះដូចតទៅ ៖

**ចៅក្រមជំនុំជំម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

កញ្ញា [redacted] ជាក្រឡាបញ្ជីអមសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជម្រះ**

សំណុំរឿងព្រហ្មទណ្ឌលេខ ៣៥៩៥ ចុះថ្ងៃទី ១៦.១១.២០១២ ដែលមានជនជាប់ចោទ ៖

ឈ្មោះ [redacted] ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតនៅសង្កាត់លេខ៥ ក្រុងភ្នំពេញ ទីលំនៅសព្វថ្ងៃផ្ទះលេខ៤១ ផ្លូវលេខ១៣៦ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ពេជ្រគង់ ( រ ) ម្តាយឈ្មោះ [redacted] ( រ ) ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ទោសពីមុនគ្មាន ជានីតិជន ។

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៧៧៣ តព្រ ចុះថ្ងៃទី ១៩.០៥.២០១៣

ជាប់ចោទពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីខែតុលា ឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

មេធាវី [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

មេធាវី [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ដើមបណ្តឹងរដ្ឋប្បវេណី

មេធាវី [redacted] តំណាងដោយអាណត្តិឲ្យក្រុមហ៊ុនសាម៉ិច ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១៤៧២ អ.យ.ធ ចុះថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០១៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២៧០៥ ជជរ ចុះថ្ងៃទី ២៨.០៨.១៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៨៥ "យ" ចុះថ្ងៃទី ២២.១០.២០១៣

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៨៦ "យ" ចុះថ្ងៃទី ២២.១០.២០១៣



Scanned by CamScanner

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា ៖ ខ្ញុំត្រូវគេចាប់ខ្លួនដោយចោទពីបទ ចេញសែកអត់លុយ ។ នៅពេលសមត្ថកិច្ចចាប់ខ្លួនខ្ញុំគឺអត់មានដីកាចាប់ , នាំនោះទេ ហើយឲ្យខ្ញុំផ្តិតមេដៃ ហើយពេលខ្ញុំមកដល់តុលាការខ្ញុំបានប្រាប់ថា ខ្ញុំមិនបានទទួលដីកាកោះនោះទេ ដោយមានមេធាវីឈ្មោះ [redacted] ហើយសមត្ថកិច្ចនៅមហាផ្ទៃបានប្រាប់ថាបានចេញដីកាកោះខ្ញុំបាន ០២.០៣ដង មកហើយ ទើបសម្រេចដល់នាំខ្លួនខ្ញុំ ។ ខ្ញុំបាទទៅទាក់ទងជាមួយក្រុមហ៊ុនសាវីមិច ហើយខ្ញុំជាឈ្មួញកណ្តាល ហើយបានរំលោភលើទំនុកចិត្តខ្ញុំដោយលួចអតិថិជនខ្ញុំបាទដោយខ្ញុំបានប្តឹងគាត់ពីបទគំរាមកំហែង ក្រោយមកគាត់ក៏យកសែកនោះមកប្តឹងខ្ញុំវិញ នេះដោយសារគាត់មានគំនុំជាមួយខ្ញុំបាទ ។ ខ្ញុំបាទធ្វើកិច្ចសន្យាហើយបញ្ជូនមក Mail ខ្ញុំ ហើយសួរលេខសែកខ្ញុំបាទ ហើយខ្ញុំក៏យល់ព្រមចុះហត្ថលេខាលើសែក និងកិច្ចសន្យា ខ្ញុំក៏បានឲ្យសែកចំនួស ១១សន្លឹក សំរាប់ទូទាត់ថ្លៃប្រេង ចំនួន ១៦ម៉ឺនដុល្លាជាង និងសែកតំកល់ជាង ១០ម៉ឺនដុល្លាអាមេរិកទៀត មានធនាគារអេស៊ីលីដា , វឌ្ឍនៈ ខ្ញុំជាអ្នកសារសា ។ ដោយសារគាត់ចង់បានប្លង់តំកល់ តែក្រុមហ៊ុនខ្ញុំគ្មានប្លង់តំកល់ ទើបដាក់សែកតំកល់ទុក ។ សែកនេះ ១១សន្លឹកជាសែកបញ្ជាទិញ ។ កន្លងមកខ្ញុំមិនបានទំនាក់ទំនងផ្ទាល់ជាមួយគាត់ទេ គឺជាលក្ខណៈគ្រួសារតាមរយៈប្រគល់លុយសុទ្ធខ្លះ ហើយក្រោយមកខ្ញុំក៏ជួបគាត់ផ្ទាល់ ហើយពេលខ្ញុំទៅជួបគាត់ គាត់បានដណ្តើមសែកពីខ្ញុំបាទ ដោយយកសែកទៅទុក។ ខ្ញុំតំកល់សែកដើម្បីចុះកិច្ចសន្យាចំណែក ១១សន្លឹកសំរាប់ទូទាត់ថ្លៃប្រេង ។ ដោយសារប្រេងមិនទាន់បានបញ្ជូនទៅទើបខ្ញុំមិនទាន់បញ្ចូលប្រាក់ទៅឲ្យគាត់ ។ ទើបតែលើកនេះខ្ញុំទាក់ទងទៅលោក [redacted] ផ្ទាល់ ។ រាល់ដងខ្ញុំទាក់ទងទៅនឹងក្រុមហ៊ុនសាវីមិច ។ ខ្ញុំបាទបញ្ជាឲ្យទិញប្រេងពីក្រុមហ៊ុនសាវីមិច ដោយចេញ ១១សន្លឹក និងតំកល់ ១សន្លឹក ដើម្បីឲ្យទុកចិត្ត ។ ដោយសារគាត់បានរំលោភលើទំនុកចិត្ត ហើយខ្ញុំមិនសុខចិត្តក៏ប្តឹងគាត់មានការប៉ះពាល់សំដីគ្នា ទើបគាត់យកសែកនោះមកប្តឹងខ្ញុំ ។ ចំពោះសែក ១១សន្លឹក ខ្ញុំមិនបានទទួលប្រេងទេ គាត់មិនព្រម ប្រគល់ប្រេងឲ្យខ្ញុំ ព្រោះមានទំនាស់នឹងគ្នា ។ ខ្ញុំមិនទទួលស្គាល់ចម្លើយនៅអយ្យការ និងខ្ញុំសូមបដិសេធចម្លើយនៅចៅក្រមស៊ើបសួរ ខ្ញុំសូមរក្សាចម្លើយ នៅក្នុងពាក្យបណ្តឹងតបខ្ញុំទុកដដែល ។ ខ្ញុំទាក់ទងទៅនឹងតំណាងក្រុមហ៊ុន សាវីមិច តែមិនទាន់បានចុះកិច្ចសន្យាជាមួយគ្នាទេ ។ បើខ្ញុំមិនទាន់បានទទួលទំនិញហេតុអីខ្ញុំត្រូវបញ្ចូលមឹកប្រាក់ទៅឲ្យគាត់ ។

-ក្រឡាបញ្ជីបានអានកំណត់ហេតុសួរចម្លើយជនជាប់ចោទនៅអយ្យការ និងចៅក្រមស៊ើបសួរ ។

-មេធា [redacted] ណាងដោយអាណត្តិឲ្យដើមបណ្តឹងបញ្ជាក់ថា ៖ នៅក្នុងរឿងនេះលោក [redacted] បានទាក់ទងទិញប្រេងក្រុមហ៊ុនសាវីមិច ជាដំណាក់កាលៗ សរុបចំនួន ១៦០,០០០លីត្រ ។ ក្រោយពីទិញប្រេងរួចឈ្មោះ [redacted] បានទូទាត់ថ្លៃប្រេងតាមរយៈមូលប្បទានប័ត្រ ជាបន្តបន្ទាប់ សរុបចំនួន ១០ សន្លឹក ក្រោយពីទទួលមូលប្បទានប័ត្រទាំងនោះហើយ ក្រុមហ៊ុនសាវីម៉ិច បានទៅបើកប្រាក់នៅធនាគារ តែត្រូវខាងធនាគារបញ្ជាក់ថា មូលប្បទានប័ត្រទាំងនេះ ពុំមានសាច់ប្រាក់ក្នុងគណនីនោះទេ ក្រោយមកក្រុមហ៊ុនបានព្យាយាមទាក់ទងជាមួយឈ្មោះ [redacted] ពីរឿងទូទាត់ថ្លៃប្រេង តែឈ្មោះនេះបានគេចវេសរហូត ។

-ក្រឡាបញ្ជីអានលិខិតបង្វិលមូលប្បទានប័ត្រត្រឡប់ ។

-ក្រឡាបញ្ជីអានប័ណ្ណបញ្ជាទិញទំនិញរបស់ក្រុមហ៊ុនសាវីម៉ិច ។

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ

ឆ្លងតាមសវនាការរួចមក យល់ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើចេញ សែកអត់លុយឲ្យទៅដើមបណ្តឹងប្រាកដមែន ដូច្នេះតំណាងអយ្យការសម្រេចតំកល់ការចោទប្រកាន់ និងដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងសុំឲ្យផ្តន្ទាទោសតាមច្បាប់ ។

មេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងបានធ្វើសេចក្ដីសន្និដ្ឋាន

ក្រោយពីបានស្ដាប់ការសួរដេញដោលរួចមក ឃើញថា លោ[redacted]បានឆ្លើយបដិសេធ រាល់ឯកសារដែលបានឃើញ ដោយមិនមានភស្ដុតាង និងឯកសារណាមកបញ្ជាក់នោះទេ ដូចនេះ សុំឲ្យតុលាការដាក់ទោសអតិបរមានៃទោស និងសងសំណង ១៦៤៣៦៨ ដុល្លាអាមេរិក ការប្រាក់ចាប់ពីថ្ងៃគាត់សងគ្រប់ និងសំណងជម្ងឺចិត្ត ៥ម៉ឺនដុល្លាអាមេរិក ។

ជនជាប់ចោទសំណូមពរ បដិសេធការចោទប្រកាន់របស់ដើមបណ្ដឹង និងសូមរក្សាសំណូមពរបណ្ដឹងតប។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានលិខិតមូលប្បទានប័ត្រក្រឡប់

-ក្រោយពីបានស្ដាប់អំណានប័ណ្ណបញ្ជាទិញរបស់ក្រុមហ៊ុនសាម៉ិច

-ក្រោយពីបានស្ដាប់តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំ

-ក្រោយពីបានស្ដាប់មេធាវីធ្វើសេចក្ដីសន្និដ្ឋាន

-ក្រោយពីបានស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារផ្សេងៗក្នុងសំណុំរឿង

**<u>សំអាងហេតុ</u>**

១-កាលពីអំឡុងខែតុលា ឆ្នាំ២០១២ ស្ថិតនៅចំណុចរាជធានីភ្នំពេញ ពិតជាមានករណី ចេញមូលប្បទានប័ត្រ ចំនួន ១០សន្លឹកដោយគ្មានសាច់ប្រាក់ក្នុងគណនី ប្រាកដមែន ដោយមានមូលប្បទានប័ត្រលេខ ២៦៤២១៣ , លេខ ២៦៤២១៤ , លេខ ២៦៤២១៥ , លេខ ២៦៤២១៩ , លេខ ២៦៤២២០ , លេខ ២៦៤២២១ , លេខ ១០៧២៧៦ , លេខ ១០៧២៧៣ , លេខ ១០៧២៧៤ និងលេខ ១០៧២៧៥ ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោ[redacted]ប្រាកដមែន ។

២-ជនជាប់ចោទបានឆ្លើយនៅពេលសវនាការថា ពិតជាបានចេញមូលប្បទានប័ត្រចំនួន ១១សន្លឹក ប្រាកដមែន ដោយមួយសន្លឹកសម្រាប់ដាក់តម្កល់មានទឹកប្រាក់ ១០ម៉ឺនដុល្លាអាមេរិក និង ១០សន្លឹកទៀត សម្រាប់ទូទាត់ថ្លៃប្រេង ១៦ម៉ឺនដុល្លាអាមេរិកជាង ។ ពេលមុននឹងចុះហត្ថលេខាលើសែកម្ចាស់ក្រុមហ៊ុនសាម៉ិចបានផ្ញើសារអេឡិចត្រូនិច មកខ្លួនសួរលេខសែកខ្លួនរួច ខ្លួនក៏យល់ព្រមចុះហត្ថលេខាលើសែក ហើយពេលខ្លួនទៅជួបម្ចាស់ក្រុមហ៊ុនសាម៉ិច គាត់បានដណ្ដើមសែកពីខ្លួន ដោយយកសែកទៅទុក ។ ហើយដោយសារប្រេងមិនទាន់បានបញ្ជូនទៅ ទើបខ្លួនមិនទាន់បញ្ចូលប្រាក់ទៅឲ្យគាត់ ។ ខ្លួនមិនទទួលស្គាល់ចម្លើយនៅអយ្យការ និងសុំបដិសេធចម្លើយនៅចៅក្រមស៊ើបសួរ ខ្លួនសុំរក្សាចម្លើយក្នុងពាក្យបណ្ដឹងតបរបស់ខ្លួនទុកនៅដដែល ។ ចំពោះចម្លើយរបស់ជនជាប់ចោទមានការប្រែប្រួលគ្មានភាពស៊ីសង្វាក់ ហើយឆ្លើយគ្មានមូលដ្ឋានដែលមិនអាចជឿជាក់បាននោះទេ ដោយហេតុថា គ្មាននរណាម្នាក់នៅពេលដែលគេដណ្ដើមយកសែក ហើយនៅស្ងៀមដោយមិនមានសកម្មភាពតបតនោះទេ ហើយជនជាប់ចោទក៏បានទទួលស្គាល់ថាសែកទាំងនោះខ្លួនជាអ្នកសរសេរ និងចុះហត្ថលេខា ។ មួយវិញទៀត ជនជាប់ចោទបានឆ្លើយថាដោយសារ ខាងក្រុមហ៊ុនសាម៉ិចមិនបានបញ្ចូលប្រេងតាមការបញ្ជាទិញ ទើបខ្លួនមិនទាន់បញ្ចូលប្រាក់ទៅឲ្យគាត់ ការឆ្លើយនេះជនជាប់ចោទគ្មានភស្ដុតាង និងសាក្សីជាអតិថិជនរបស់ជនជាប់ចោទមកបញ្ជាក់អះអាងនោះទេ គឺជនជាប់ចោទអះអាងដោយខ្លួនឯង ។ ប៉ុន្តែការឆ្លើយរបស់មេធាវីខាងក្រុមហ៊ុនសាម៉ិច គឺខាងក្រុមហ៊ុនបានផ្គត់ផ្គង់ប្រេងឥន្ធនៈគ្រប់ចំនួនតាមការបញ្ជាទិញដែលមានទឹកប្រាក់ក្នុង



Scanned by CamScanner

សែក ដែលឈ្មោះ [redacted] បានបញ្ជាទិញពីខាងក្រុមហ៊ុន ហើយខាងក្រុមហ៊ុនមានភស្តុតាងជាប័ណ្ណបញ្ជាទិញទៅឲ្យអតិថិជនរបស់ឈ្មោះ [redacted] ចំនួន ១០សន្លឹក ហើយតម្លៃដែលមានក្នុងប័ណ្ណបញ្ជាទិញនីមួយៗត្រូវគ្នានឹងចំនួនទឹកប្រាក់ក្នុងសែកនីមួយៗ ដែលឈ្មោះ [redacted] បានចេញឲ្យហើយរាល់ការបញ្ជាទិញប្រេងរបស់ឈ្មោះ [redacted] គឺខាងក្រុមហ៊ុនតម្រូវឲ្យចេញសែកជាមុន ដែលកំណត់រយៈពេល ១ខែ ទើបអាចបើកប្រាក់បានរួចទើបខាងក្រុមហ៊ុនបញ្ចេញទំនិញទៅឲ្យតាមការបញ្ជាទិញ ។ ជាក់ស្តែងតាមការពិនិត្យទៅលើប័ណ្ណបញ្ចេញទំនិញរបស់ក្រុមហ៊ុនសារ៉ៃម៉ិចចំនួន ១០សន្លឹក ដែលបានបញ្ជូនប្រេងទៅឲ្យអតិថិជនតាមការបញ្ចេញទំនិញរបស់ឈ្មោះ [redacted] ឃើញថា ត្រូវគ្នាជាមួយនឹងមូលប្បទានប័ត្រ ចំនួន ១០សន្លឹក ដែលឈ្មោះ [redacted] បានបញ្ជាទិញប្រេងពីក្រុមហ៊ុនសារ៉ៃម៉ិច ។ ហេតុដូច្នេះចម្លើយរបស់ជនជាប់ចោទជាចម្លើយដោះសារគ្មានភស្តុតាង ឬសាក្សីណាមួយដែលអាចឲ្យយកមកពិចារណាបានទេ ។

៣-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ពិតជាបានចេញមូលប្បទានប័ត្រចំនួន ១០សន្លឹក ទៅឲ្យក្រុមហ៊ុនសារ៉ៃម៉ិច ដោយគ្មានសាច់ប្រាក់ក្នុងគណនី ប្រាកដមែន ដោយឈ្មោះ [redacted] បានចេញមូលប្បទានប័ត្របញ្ជាទិញប្រេងពីក្រុមហ៊ុនសារ៉ៃម៉ិច ហើយពេលក្រុមហ៊ុនបានទទួលបញ្ជាទិញដោយការប្រគល់មូលប្បទានប័ត្រនោះ ខាងក្រុមហ៊ុនបានបញ្ចេញប្រេងទៅតាមការបញ្ជាទិញរបស់ឈ្មោះ [redacted] គ្រប់ចំនួន ប៉ុន្តែដល់ពេលទៅបើកប្រាក់ ក្នុងមូលប្បទានប័ត្រ ខាងធនាគារបង្វិលមូលប្បទានប័ត្រមកវិញ ថាគ្មានសាច់ប្រាក់នោះទេ ។ ដូច្នេះអំពើរបស់ជនជាប់ចោទ គឺជាការមិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ដែលបានធ្វើឲ្យខូចប្រយោជន៍ក្រុមហ៊ុនសារ៉ៃម៉ិច ។ ដូច្នេះអំពើរបស់ជនជាប់ចោទឈ្មោះ [redacted] បានរំលោភទៅលើមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

៤-លោកតំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើចេញសែកអត់លុយឲ្យទៅដើមបណ្តឹងប្រាកដមែន ដូច្នេះតំណាងអយ្យការសម្រេចតក់កល់ការចោទប្រកាន់ និងដីកាសន្និដ្ឋានស្ថាពរទុកជាបានការ ដដែល និងសុំឲ្យផ្តន្ទាទោសតាមច្បាប់ តប្បីតុលាការពិចារណាតាមផ្លូវច្បាប់ ។

៥-មេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹង លោក [redacted] បានឆ្លើយបដិសេធ រាល់ឯកសារដែលបានឃើញ ដោយមិនមានភស្តុតាង និងឯកសារណាមកបញ្ជាក់នោះទេ ដូចនេះ សុំឲ្យតុលាការដាក់ទោសអតិបរមានៃទោស និងសងសំណង ១៦៨៣៦៨ ដុល្លារអាមេរិក ការប្រាក់ចាប់ពីថ្ងៃគាត់សងគ្រប់ និងសំណងជម្ងឺចិត្ត ៥ម៉ឺនដុល្លារអាមេរិក ។ តប្បីតុលាការពិចារណា ។

៦-សំដីចុងក្រោយរបស់ជនជាប់ចោទបានសុំបដិសេធការចោទប្រកាន់របស់ដើមបណ្តឹង និងសុំអាក្សាសំណូមពរបណ្តឹងតប តប្បីតុលាការពិចារណាតាមច្បាប់ ។

៧-មានពិរុទ្ធភាពគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីខែតុលា ឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញបាន និងប្រត្តិបត្តិការទូទាត់សងប្រាក់ ។

៨-ជនជាប់ចោទឈ្មោះ [redacted] ត្រូវបានតំណាងអយ្យការធ្វើការចោទប្រកាន់ជាច់ពីគ្នា ហើយត្រូវបានរកឃើញមានពិរុទ្ធភាព បទល្មើសច្រើន និងត្រូវបានផ្តន្ទាទោសតាមអំណាចសាលក្រមលេខ ៤៥ "យ" ចុះថ្ងៃទី ២២.១០.២០១៣ ដាក់ពន្ធនាគារ ០១ឆ្នាំ ០៦ខែ និងសាលក្រមលេខ ៤៦ "យ" ចុះថ្ងៃទី ២២.១០.២០១៣ ដាក់ពន្ធនាគារ ០១ឆ្នាំ ០៦ខែ ដែលមានទាន់ចូលជាស្ថាពរ ។ ដូច្នេះ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ដែលត្រូវបានរកឃើញថា មានពិរុទ្ធភាពពីបទល្មើសច្រើន គឺបទល្មើសត្រួតគ្នានៃការចោទប្រកាន់ដាច់ពីគ្នា។ ដូច្នេះមាត្រា ១៣៦ និងមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌត្រូវយកមកអនុវត្ត។



Scanned by CamScanner

## ហេតុដូច្នេះសម្រេច

១/ទណ្ឌកម្មដាក់ពន្ធនាគារលើពិរុទ្ធជនឈ្មោះ [redacted] តាមសាលក្រមលេខ ៨៥ "យ" ចុះថ្ងៃទី ២២.១០.២០១៣ និងសាលក្រមលេខ ៨៦ "យ" ចុះថ្ងៃទី ២២.១០.២០១៣ ត្រូវអនុវត្តទោសស្រួតគ្នា ដោយស្រូបបញ្ចូលគ្នាក្នុងទណ្ឌកម្មដាក់ពន្ធនាគារនៃការផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ក្នុងសាលក្រមនេះ យោងតាមមាត្រា ១៣៦ និង មាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ ។

២/ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារដោយស្រូបបញ្ចូលគ្នាជាមួយសាលក្រមលេខ ៨៥ "យ" ចុះថ្ងៃទី ២២.១០.២០១៣ និងសាលក្រមលេខ ៨៦ "យ" ចុះថ្ងៃទី ២២.១០.២០១៣ និងសាលក្រមនេះ កំណត់រយៈពេលចំនួន ០២ឆ្នាំ ០៦ខែ ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីខែតុលា ឆ្នាំ២០១២ តាមមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រត្តិបត្តិការទូទាត់សងប្រាក់ និងមាត្រា ១៣៦ និងមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ

៣/បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] សងសំណងការខូចខាតចំនួន ១៦៨៣៦៨ ដុល្លា(មួយសែនប្រាំមួយម៉ឺនបួនពាន់បីរយហុកសិបប្រាំមួយដុល្លាអាមេរិក) និងសំណងជម្ងឺចិត្តចំនួន ២០០០ដុល្លា(ពីរពាន់ដុល្លាអាមេរិក) ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី ក្រុមហ៊ុនសាមីុច អាហារ័ណ នីហារ័ណ ប្រេងឥន្ធនៈ ពេលសាលក្រមចូលស្ថាពរ ។ ការទាមទារលើពីនេះច្រានចោល ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

**ក្រឡាបញ្ជី**

ហត្ថលេខា និងត្រា [redacted]

បានឃើញ

ចៅក្រម

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០១៣

ក្រឡាបញ្ជី

[redacted]



Scanned by CamScanner